ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩២ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈបញ្ជាការការពារសន្តិសុខគោលដៅ ទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- អនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ៣៤ សសរ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលសមាសភាពគណៈបញ្ជាការការពារសន្តិសុខគោលដៅទីស្តីការគណៈរដ្ឋមន្ត្រីនិងទីស្តីការនាយករដ្ឋមន្ត្រី
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលសមាសភាពគណៈបញ្ជាការការពារសន្តិសុខគោលដៅទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី ដូចមានរាយនាមខាងក្រោម៖

១- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការបញ្ជាការដ្ឋានអង្គរក្ស ជាប្រធាន

២- ឯកឧត្តមនាយឧត្តមសេនីយ៍ **យូ ស៊ិនឡុង** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រធានក្រុមការងារចុះរៀបចំកិច្ចការសន្តិសុខសុវត្ថិភាពតាមគោលដៅប្រារព្ធពិធីក្នុងព្រះរាជាណាចក្រកម្ពុជា ជាអនុប្រធាន

៣- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ុយ ពិសិដ្ឋ** រដ្ឋលេខាធិការក្រសួងការពារជាតិប្រចាំការដឹកនាំបញ្ជាបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន

៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ីង ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក និងជាមេបញ្ជាការបញ្ជាការដ្ឋានជាតិកម្លាំងពិសេសប្រឆាំងភេរវកម្ម ជាអនុប្រធាន

៥- ឯកឧត្តម **ឃឹម វុឌ្ឍីដា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មការសម្របសម្រួល ប្រើប្រាស់ និងសម្របសម្រួលពិធីនិងកិច្ចប្រជុំនានានៅវិមានសន្តិភាព ជាអនុប្រធាន

៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **តាន់ បញ្ញារិទ្ធ** នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាអនុប្រធាន

៧- ឯកឧត្តម **សេង ឡៅង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីនិងជានាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាអនុប្រធាន ទទួលសម្របសម្រួលការងារទូទៅនិងផ្គត់ផ្គង់

៨- ឯកឧត្តម **ម្លូន លឹមហេង** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធាន ទទួលការងារជានាផ្គត់ផ្គង់និងហិរញ្ញវត្ថុ

៩- ឯកឧត្តមឧត្តមសេនីយ៍ឯក **ចៅ កុល** នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនិងជាមេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន

១០- ឯកឧត្តមឧត្តមសេនីយ៍ឯក **ស ថេត** អគ្គស្នងការរងនគរបាលជាតិនិងជាស្នងការនគរបាលរាជធានីភ្នំពេញ ជាអនុប្រធាន

១១- ឯកឧត្តម **ឃួន ចាន់យ៉ាដា** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ ជាអនុប្រធាន ទទួលការងារក្តាប់ព័ត៌មានទូទៅ ទប់ស្កាត់ ដោះស្រាយរាល់បាតុភាព និងរាល់ពាក្យបណ្តឹងផ្សេងៗ

១២- ឯកឧត្តមឧត្តមសេនីយ៍ឯក **អ៊ឹង សារិទ្ធ** មេបញ្ជាការរងនិងជានាយសេនាធិការបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន ទទួលផែនអន្តរាគមន៍

១៣- ឯកឧត្តមឧត្តមសេនីយ៍ឯក **តោគ ចន្ថា** មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធានអចិន្ត្រៃយ៍ ទទួលដឹកនាំបញ្ជាកម្លាំងការពារសន្តិសុខក្នុងបរិវេណទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី

១៤- ឯកឧត្តមឧត្តមសេនីយ៍ឯក **សុខ ធារុណ្ណា** មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន ទទួលផែនសន្តិសុខផ្ទាល់

| | | | |
|---|---|---|---|
| ១៥- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ពូ សាម៉ុនឌី** | មេបញ្ជាការរងកងទ័ពជើងគោក និងជាមេបញ្ជាការយោធភូមិភាគពិសេស | ជាអនុប្រធាន |
| ១៦- | ឯកឧត្តមឧត្តមសេនីយ៍ឯក **រ័ត្ន ស្រ៊ាង** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ | ជាអនុប្រធាន |
| ១៧- | ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុន.រ៉ា** | មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស | ជាសមាជិក ទទួលការងារស្រាវជ្រាវ |
| ១៨- | ឧត្តមសេនីយ៍ឯក **សំ ស៊ីយ៉ាន** | ប្រធាននាយកដ្ឋាននគរបាលការពារ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | ជាសមាជិក |
| ១៩- | ឧត្តមសេនីយ៍ឯក **ឆាន់ លី** | មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស | ជាសមាជិក |
| ២០- | ឧត្តមសេនីយ៍ឯក **សៅ ភក្តុជា** | មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស | ជាសមាជិក |
| ២១- | ឧត្តមសេនីយ៍ឯក **សំ សារឿន** | មេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស | ជាសមាជិក |
| ២២- | ឧត្តមសេនីយ៍ទោ **ស៊ឹម ម៉ុនផន** | មេបញ្ជាការរងបញ្ជាការដ្ឋានជាតិ កម្លាំងពិសេសប្រឆាំងភេរវកម្ម | ជាសមាជិក |
| ២៣- | ឧត្តមសេនីយ៍ទោ **ឡេង ហុង** | មេបញ្ជាការរងកងអន្តរាគមន៍លេខ៩ ការពារសន្តិសុខគោលដៅទីស្តីការនាយករដ្ឋមន្ត្រី និងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក។ |

**ប្រការ២ .-**

គណៈបញ្ជាការនេះមានភារកិច្ចដូចខាងក្រោម ៖

- ការពារសន្តិសុខ សុវត្ថិភាព នៅក្នុងនិងជុំវិញទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី ២៤ម៉ោង លើ២៤ម៉ោង
- គ្រប់គ្រងកងកម្លាំងប្រដាប់អាវុធទាំងអស់ដែលមានភារកិច្ចទទួលខុសត្រូវការពារក្នុងទីស្តីការនាយករដ្ឋមន្ត្រី និងទីស្តីការគណៈរដ្ឋមន្ត្រី
- ពិនិត្យជាតិផ្ទុះ ជាតិពុល ព្រមទាំងឆែកឆេររាល់សម្ភារៈ មធ្យោបាយ និងសមាសភាពទាំងអស់ដែលចេញ-ចូលក្នុងបរិវេណទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី
- សហការជាមួយគណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួលពិធីនិងកិច្ចប្រជុំនានាក្នុងអគារសន្តិភាពនិងអគារមិត្តភាព
- សហការជាមួយសមត្ថកិច្ច អាជ្ញាធរដែនដីពាក់ព័ន្ធ តាមដានក្តាប់សភាពការណ៍ ព្រមទាំងទប់ស្កាត់រាល់សកម្មភាពភូដកម្ម បាតុកម្ម និងការតវ៉ាផ្សេងៗ ដែលនាំឱ្យប៉ះពាល់ដល់ការរៀបចំពិធីក្នុងទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី
- ពិនិត្យរាល់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិកសន្តិសុខ នៅក្នុងនិងជុំវិញទីស្តីការនាយករដ្ឋមន្ត្រីនិងទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ៣ .-**

គណៈបញ្ជាការនេះមានសិទ្ធិប្រើត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**ប្រការ៤ .-**

អនុប្រធាននិងសមាជិកត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានគណៈបញ្ជាការ។

**ប្រការ៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣កើតខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ